ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
№ ៧៧៦ ឧ.ក.រ.ថ.ស.ប

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៩

# អាជ្ញាបណ្ណស្វែងរុករក

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ។
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។
- បានឃើញកិច្ចព្រមព្រៀងស្តីពីការសិក្សាស្រាវជ្រាវរ៉ែលោហៈនៅតំបន់កង់រ៉ូឡង់ ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី រវាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រុមហ៊ុន Summer Gold Investment Pvt. Ltd. ចុះថ្ងៃទី 29 JUL 2009 ។

### សម្រេច

ប្រការ១: អនុញ្ញាតអោយក្រុមហ៊ុន Summer Gold Investment Pvt. Ltd. មានអាសយដ្ឋាននៅផ្ទះលេខ ១៥ ផ្លូវ៣០២ សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ធ្វើការសិក្សាស្រាវជ្រាវរ៉ែលោហៈនៅតំបន់កង់រ៉ូឡង់ ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី លើផ្ទៃដីទំហំ ១៣៦ (មួយរយ-សាមសិបប្រាំមួយ) គីឡូម៉ែត្រក្រឡា ដែលមានកូអរដោណេដូចតទៅ :

| ចំណុច | អាប់ស៊ីស | អ័រដោរណេ | ចំណុច | អាប់ស៊ីស | អ័រដោរណេ |
|---|---|---|---|---|---|
| A | 6 78 000 | 14 17 000 | C | 6 95 000 | 14 09 000 |
| B | 6 95 000 | 14 17 000 | D | 6 78 000 | 14 09 000 |

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ១៤១ ទូរសារ: (៨៥៥)២៣ ៤២៨ ២៦៣
45 Preah Norodom Boulivard. Khan Daun Penh. Phone: (855) 23 211 141 Fax: (855) 23 428 263

**<u>ប្រការ២:</u>** ក្រុមហ៊ុនត្រូវដំណើរការសិក្សាស្រាវជ្រាវរ៉ែលើផ្ទៃដីដែលបានកំណត់ខាងលើ ដោយអនុវត្តទៅតាមផែនការឆ្នាំ និងកម្មវិធីការងាររបស់ខ្លួនដោយធានាអនុវត្តតាមបទដ្ឋានបច្ចេកទេសក្នុងការសិក្សាស្រាវជ្រាវរុករករ៉ែ ។

**<u>ប្រការ៣:</u>** អាជ្ញាប័ណ្ណនេះមានតំលៃរយៈពេល០២ (ពីរ) ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខា ។ មុនផុតកំណត់៣០ថ្ងៃ ក្រុមហ៊ុនត្រូវដាក់ពាក្យសុំអនុញ្ញាតធ្វើការសិក្សាស្រាវជ្រាវរ៉ែបន្តជាថ្មី ។

**<u>ប្រការ៤:</u>** ក្នុងករណីប្រព្រឹត្តល្មើសលើល័ក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៩ អាជ្ញាប័ណ្ណនេះនឹងត្រូវដកហូត ឬត្រូវពិន័យទៅតាមច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ។

**<u>ប្រការ៥:</u>** អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានរ៉ែ អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តមណ្ឌលគិរី និងក្រុមហ៊ុន Summer Gold Investment Pvt. Ltd. ត្រូវទទួលអនុវត្តអាជ្ញាប័ណ្ណនេះ តាមភារៈកិច្ចរៀងៗខ្លួន។

**<u>ប្រការ៦:</u>** អាជ្ញាប័ណ្ណនេះមានអនុភាពគតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ស៊ុយ សែម

**<u>ចំលងជូន</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងបរិស្ថាន
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- សាលាខេត្តមណ្ឌលគិរី
- សាលាស្រុកពេជ្រាដា
- ដូចប្រការ៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ